សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

ACP
P.O. Box 9120
Chelsea, Massachusetts 02150-9120
617-727-3261
1-866-SAFE-ADD
គេហទំព័រ៖ www.sec.state.ma.us/acp

ខិត្តប័ណ្ណ ACP

បានធ្វើបច្ចុប្បន្នភាពថ្ងៃទី19 ខែមករា ឆ្នាំ2023

ភាសាខ្មែរ

**1-866-SAFE-ADD**

# កម្មវិធីរក្សាការសម្ងាត់អាសយដ្ឋាន




William Francis Galvin
រដ្ឋលេខាធិការនៃខមមិនវែល

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

ACP
P.O. Box 9120
Chelsea, Massachusetts 02150-9120
617-727-3261
1-866-SAFE-ADD
គេហទំព័រ៖ www.sec.state.ma.us/acp

ខិត្តប័ណ្ណ ACP

បានធ្វើបច្ចុប្បន្នភាពថ្ងៃទី19 ខែមករា ឆ្នាំ2023

ភាសាខ្មែរ

1-866-SAFE-ADD

កម្មវិធីរក្សាការសម្ងាត់អាសយដ្ឋាន




William Francis Galvin
រដ្ឋលេខាធិការនៃខមមិនវែល

# កម្មវិធីរក្សាការសម្ងាត់អាសយដ្ឋាន

## តើជាកម្មវិធីអ្វី?

កម្មវិធីរក្សាការសម្ងាត់អាសយដ្ឋាន (ACP) មានបំណងផ្តល់ជូនមធ្យោបាយ ដែលអ្នករួចផុតពីគ្រោះថ្នាក់នៃអំពើហិង្សាក្នុងគ្រួសារ ការរំលោភបំពានផ្លូវភេទ ការចាប់រំលោភ ឬការឈ្លបចាប់ ឬអ្នកដែលចូលរួមក្នុងសេវាកម្មថែទាំសុខភាពបន្តពូជ និងការថែទាំពាក់ព័ន្ធនឹងយេនឌ័រដែលត្រូវបានការពារស្របតាមច្បាប់ អាចប្រើប្រាស់អាសយដ្ឋានសម្ងាត់ដើម្បីបង្កើនសុវត្ថិភាព។

## តើកម្មវិធីមានដំណើរការដូចម្ដេច?

អ្នករួចផុតពីគ្រោះថ្នាក់ បំពេញពាក្យសុំកម្មវិធី ACP ជាមួយនឹងជំនួយការកម្មវិធីដែលមានការបញ្ជាក់ (AA)។ អ្នកដាក់ពាក្យត្រូវតែបង្ហាញថា ការបញ្ចេញព័ត៌មានអាសយដ្ឋានរបស់អ្នករួចផុតពីគ្រោះថ្នាក់ គឺជាការគំរាមកំហែងដល់សុវត្ថិភាពរបស់ពួកគេ។

អ្នកប្រកបវិជ្ជាជីវៈផ្នែកថែទាំសុខភាពដែលត្រូវបានការពារស្របតាមច្បាប់ មិនចាំបាច់ប្រើជំនួយការកម្មវិធីដើម្បីដាក់ពាក្យស្នើសុំ ឬបង្ហាញថាការបញ្ចេញព័ត៌មានអាសយដ្ឋានរបស់ពួកគេគំរាមកំហែងដល់សុវត្ថិភាពរបស់ពួកគេនោះទេ។

នៅពេលដែល ACP ទទួលបានពាក្យសុំ គេត្រូវត្រួតពិនិត្យពាក្យសុំនោះ។ ប្រសិនបើព្រមទទួលយក លេខាធិការនឹងផ្តល់អាសយដ្ឋានជំនួសដល់អ្នកចូលរួម ដើម្បីប្រើប្រាស់ជាអាសយដ្ឋានស្របច្បាប់របស់អ្នកចូលរួមនៅក្នុងរដ្ឋ MA។

### ACP គឺជាកម្មវិធីអ្វី៖

សេវាការបញ្ជូនសំបុត្រ

យន្តការផ្លូវច្បាប់សម្រាប់ការលុបចោលអាសយដ្ឋានរបស់អ្នកចូលរួម មិនឲ្យមានការបញ្ចេញព័ត៌មាននៅលើកំណត់ត្រាសាធារណៈដោយផ្តល់នូវអាសយដ្ឋានប្រៃសណីយ៍ដែលមានសុវត្ថិភាព

អាសយដ្ឋានដែលមានសុវត្ថិភាពសម្រាប់គោលបំណងនៃប្រតិបត្តិការ RMV

*សម្គាល់៖ ACP មិនការពារពីការបញ្ចេញព័ត៌មានរបស់អាសយដ្ឋានពីមុននោះទេ*

### ACP មិនមានកម្មវិធីអ្វីខ្លះ៖

ទីភ្នាក់ងារសេវាកម្មសង្គម

ទីភ្នាក់ងារអនុវត្តច្បាប់

កម្មវិធីការពារសាក្សី

## តើអ្នកណាអាចដាក់ពាក្យបាន?

1) អ្នករួចផុតពីគ្រោះថ្នាក់នៃអំពើហឹង្សាក្នុងគ្រួសារ ការរំលោភបំពានផ្លូវភេទ ការចាប់រំលោភ ឬការឈ្លបចាប់ ដែលពួកគេ៖
   - រស់នៅក្នុងរដ្ឋ MA
   - ថ្មីៗនេះបានផ្លាស់ប្តូរទីតាំងទៅអាសយដ្ឋានថ្មី ឬកំពុងមានបំណងផ្លាស់ប្តូរទីតាំង
   - មិនបានបញ្ចេញព័ត៌មានអាសយដ្ឋានថ្មីរបស់ពួកគេជាផ្នែកមួយនៃកំណត់ត្រាសាធារណៈណាមួយឡើយ
   - មិនបានធ្វើបច្ចុប្បន្នភាពអាសយដ្ឋានថ្មីរបស់ពួកគេជាមួយ RMV ឬ USPS
   - ដឹងថាឧក្រិដ្ឋជនមិនស្គាល់អាសយដ្ឋានថ្មី
   - អាចបង្ហាញថាការបញ្ចេញព័ត៌មានអាសយដ្ឋានគឺគំរាមកំហែងដល់សុវត្ថិភាព
2) បុគ្គលដែលបានចូលរួមក្នុងការផ្តល់ ការសម្របសម្រួល ឬការលើកកម្ពស់សេវាថែទាំសុខភាពដែលត្រូវបានការពារស្របតាមច្បាប់ រួមមាន៖
   - សេវាថែទាំសុខភាពពាក់ព័ន្ធនឹងយេនឌ័រ
   - សេវាថែទាំសុខភាពបន្តពូជ

## តើខ្ញុំដាក់ពាក្យសុំដូចម្តេច?

សម្រាប់អ្នករួចផុតពីគ្រោះថ្នាក់៖

- ទូរសព្ទទៅកាន់ការិយាល័យ ACP ដើម្បីភ្ជាប់ទំនាក់ទំនងជាមួយ AA
- ទាក់ទងទីភ្នាក់ងារ DV/SA ក្នុងរដ្ឋ MA

សម្រាប់អ្នកប្រកបវិជ្ជាជីវៈផ្នែកថែទាំសុខភាពដែលមានការការពារស្របតាមច្បាប់៖

- ចូលទៅកាន់គេហទំព័រ ACP
  **សម្គាល់៖** អ្នកប្រកបវិជ្ជាជីវៈផ្នែកថែទាំសុខភាព មិនតម្រូវឱ្យដាក់ពាក្យសុំតាមរយៈ AA នោះទេ

## សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង

Address Confidentiality Program
PO Box 9120
Chelsea, MA 02150
1-866-SAFE-ADD
617-727-3261
sec.state.ma.us/acp

*Statutory authority M.G.L. c.9A*
*Regulatory authority 950 CMR 130.00*


# កម្មវិធីរក្សាការសម្ងាត់អាសយដ្ឋាន

## តើជាកម្មវិធីអ្វី?

កម្មវិធីរក្សាការសម្ងាត់អាសយដ្ឋាន (ACP) មានបំណងផ្តល់ជូនមធ្យោបាយ ដែលអ្នករួចផុតពីគ្រោះថ្នាក់នៃអំពើហិង្សាក្នុងគ្រួសារ ការរំលោភបំពានផ្លូវភេទ ការចាប់រំលោភ ឬការឈ្លបចាប់ ឬអ្នកដែលចូលរួមក្នុងសេវាកម្មថែទាំសុខភាពបន្តពូជ និងការថែទាំពាក់ព័ន្ធនឹងយេនឌ័រដែលត្រូវបានការពារស្របតាមច្បាប់ អាចប្រើប្រាស់អាសយដ្ឋានសម្ងាត់ដើម្បីបង្កើនសុវត្ថិភាព។

## តើកម្មវិធីមានដំណើរការដូចម្ដេច?

អ្នករួចផុតពីគ្រោះថ្នាក់ បំពេញពាក្យសុំកម្មវិធី ACP ជាមួយនឹងជំនួយការកម្មវិធីដែលមានការបញ្ជាក់ (AA)។ អ្នកដាក់ពាក្យត្រូវតែបង្ហាញថា ការបញ្ចេញព័ត៌មានអាសយដ្ឋានរបស់អ្នករួចផុតពីគ្រោះថ្នាក់ គឺជាការគំរាមកំហែងដល់សុវត្ថិភាពរបស់ពួកគេ។

អ្នកប្រកបវិជ្ជាជីវៈផ្នែកថែទាំសុខភាពដែលត្រូវបានការពារស្របតាមច្បាប់ មិនចាំបាច់ប្រើជំនួយការកម្មវិធីដើម្បីដាក់ពាក្យស្នើសុំ ឬបង្ហាញថាការបញ្ចេញព័ត៌មានអាសយដ្ឋានរបស់ពួកគេគំរាមកំហែងដល់សុវត្ថិភាពរបស់ពួកគេនោះទេ។

នៅពេលដែល ACP ទទួលបានពាក្យសុំ គេត្រូវត្រួតពិនិត្យពាក្យសុំនោះ។ ប្រសិនបើព្រមទទួលយក លេខាធិការនឹងផ្តល់អាសយដ្ឋានជំនួសដល់អ្នកចូលរួម ដើម្បីប្រើប្រាស់ជាអាសយដ្ឋានស្របច្បាប់របស់អ្នកចូលរួមនៅក្នុងរដ្ឋ MA។

### ACP គឺជាកម្មវិធីអ្វី៖

សេវាការបញ្ជូនសំបុត្រ

យន្តការផ្លូវច្បាប់សម្រាប់ការលុបចោលអាសយដ្ឋានរបស់អ្នកចូលរួម មិនឲ្យមានការបញ្ចេញព័ត៌មាននៅលើកំណត់ត្រាសាធារណៈដោយផ្តល់នូវអាសយដ្ឋានប្រៃសណីយ៍ដែលមានសុវត្ថិភាព

អាសយដ្ឋានដែលមានសុវត្ថិភាពសម្រាប់គោលបំណងនៃប្រតិបត្តិការ RMV

*សម្គាល់៖ ACP មិនការពារពីការបញ្ចេញព័ត៌មានរបស់អាសយដ្ឋានពីមុននោះទេ*

### ACP មិនមានកម្មវិធីអ្វីខ្លះ៖

ទីភ្នាក់ងារសេវាកម្មសង្គម

ទីភ្នាក់ងារអនុវត្តច្បាប់

កម្មវិធីការពារសាក្សី

## តើអ្នកណាអាចដាក់ពាក្យបាន?

1) អ្នករួចផុតពីគ្រោះថ្នាក់នៃអំពើហឹង្សាក្នុងគ្រួសារ ការរំលោភបំពានផ្លូវភេទ ការចាប់រំលោភ ឬការឈ្លបចាប់ ដែលពួកគេ៖
   - រស់នៅក្នុងរដ្ឋ MA
   - ថ្មីៗនេះបានផ្លាស់ប្តូរទីតាំងទៅអាសយដ្ឋានថ្មី ឬកំពុងមានបំណងផ្លាស់ប្តូរទីតាំង
   - មិនបានបញ្ចេញព័ត៌មានអាសយដ្ឋានថ្មីរបស់ពួកគេជាផ្នែកមួយនៃកំណត់ត្រាសាធារណៈណាមួយឡើយ
   - មិនបានធ្វើបច្ចុប្បន្នភាពអាសយដ្ឋានថ្មីរបស់ពួកគេជាមួយ RMV ឬ USPS
   - ដឹងថាឧក្រិដ្ឋជនមិនស្គាល់អាសយដ្ឋានថ្មី
   - អាចបង្ហាញថាការបញ្ចេញព័ត៌មានអាសយដ្ឋានគឺគំរាមកំហែងដល់សុវត្ថិភាព
2) បុគ្គលដែលបានចូលរួមក្នុងការផ្តល់ ការសម្របសម្រួល ឬការលើកកម្ពស់សេវាថែទាំសុខភាពដែលត្រូវបានការពារស្របតាមច្បាប់ រួមមាន៖
   - សេវាថែទាំសុខភាពពាក់ព័ន្ធនឹងយេនឌ័រ
   - សេវាថែទាំសុខភាពបន្តពូជ

## តើខ្ញុំដាក់ពាក្យសុំដូចម្តេច?

សម្រាប់អ្នករួចផុតពីគ្រោះថ្នាក់៖

- ទូរសព្ទទៅកាន់ការិយាល័យ ACP ដើម្បីភ្ជាប់ទំនាក់ទំនងជាមួយ AA
- ទាក់ទងទីភ្នាក់ងារ DV/SA ក្នុងរដ្ឋ MA

សម្រាប់អ្នកប្រកបវិជ្ជាជីវៈផ្នែកថែទាំសុខភាពដែលមានការការពារស្របតាមច្បាប់៖

- ចូលទៅកាន់គេហទំព័រ ACP
  **សម្គាល់៖** អ្នកប្រកបវិជ្ជាជីវៈផ្នែកថែទាំសុខភាព មិនតម្រូវឱ្យដាក់ពាក្យសុំតាមរយៈ AA នោះទេ

## សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង

Address Confidentiality Program
PO Box 9120
Chelsea, MA 02150
1-866-SAFE-ADD
617-727-3261
sec.state.ma.us/acp

*Statutory authority M.G.L. c.9A*
*Regulatory authority 950 CMR 130.00*